ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ទំនើបកម្មការបង្រៀន និងរៀន សម្រាប់សតវត្សថ្មី

## សាលារៀនជំនាន់ថ្មី

បាត់ដំបង, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣

# តើអ្វីទៅជាវិធីជួយដល់ការបង្រៀនទំនើបក្នុងសាលាជំនាន់ថ្មី?

ទោះបីជាសាលាជំនាន់ថ្មីគាំទ្រវិធីសាស្រ្តបង្រៀនជាក់លាក់ក៏ដោយ វិធីសាស្រ្តទាំងនេះមិនកើតឡើងតែឯងនោះទេ។ វិធីសាស្រ្តច្រើនត្រូវបានប្រើដើម្បីពង្រឹងគ្នាទៅវិញទៅមក។




shutterstock.com · 360045515

# វិធីដែលគាំទ្រការបង្រៀន និងរៀនទំនើប



# តើអ្វីទៅជាប្រព័ន្ធអេកូគរុកោសល្យ?

រូបភាពប្រព័ន្ធអេកូស៊ីស្តែមនៃការសិក្សា




ការកែលម្អប្រកបដោយជោគជ័យនៅក្នុងបរិយាកាសសិក្សារបស់ NGS គឺមួយចំណែកកើតចេញពីការប្រើប្រាស់វិធីសាស្រ្តសិក្សាថ្មីៗ។

ចំណែកដ៏ធំជាងនេះគឺកើតចេញពីការបង្កើតប្រព័ន្ធអេកូគរុកោសល្យដោយសាលារៀនជំនាន់ថ្មីដើម្បីគាំទ្រវិធីសាស្រ្តបង្រៀនថ្មីៗ

# វិធីសាស្ត្របៀបបាននឹងគ្រាប់ពូជ. . .




- គ្រាប់ពូជមួយអាចដុះលូតលាស់ទៅជារុក្ខជាតិដែលមានសុខភាពល្អបាន ប្រសិនបើបរិស្ថានផ្តល់ការគាំទ្រគ្រប់គ្រាន់ . .
- ដូចគ្នានោះដែរ ការបណ្តុះបណ្តាលតែឯងដោយមើលរំលងកត្តាជាច្រើននៅក្នុងសាលារៀនអាចបំផ្លាញជាតុចូលបែបនេះ។

# ធាតុនៃប្រព័ន្ធអេកូគរុកោសល្យនៅក្នុងសាលាជំនាន់ថ្មី. . .

បរិយាកាសគាំទ្រដែលបង្កើតឡើងដោយប្រព័ន្ធអេកូគរុកោសល្យនេះគឺជាអ្វីដែលជំរុញការរៀនសូត្រឱ្យប្រសើរឡើង។

**អភិបាលកិច្ចគឺជាគន្លឹះ:**

- ការទទួលស្គាល់គុណភាពសាលា
- ការភ្ជាប់ការលើកទឹកចិត្តទៅនឹងការអនុវត្តការងារ
- ការបង្កើនម៉ោងបង្រៀន
- គ្មានការបង្រៀនក្នុងឯកជន




វិធីសាស្ត្រថ្មីដែលគាំទ្រដោយ NGS គឺគ្រាន់តែជាធាតុមួយនៅពីក្រោយភាពជោគជ័យនៃការសិក្សារបស់សិស្ស។

# របៀបដែលចិត្តដូចគ្នាក្នុងចំណោមគ្រូបង្រៀនជំរុញឱ្យមានការផ្លាស់ប្តូរ. . .

- គោលការណ៍នៃការគិតដូចគ្នាបង្កើតឱ្យមានចលនាពង្រឹងខ្លួនឯងដោយរស់រវើកក្នុងសាលាជំនាន់ថ្មី ...
- នេះមានន័យថា នៅពេលដែលគ្រូជាច្រើនមានគំនិតស្រដៀងគ្នាអំពីការបង្រៀន ពួកគេនឹងពង្រឹង និងគាំទ្រគ្នាទៅវិញទៅមក។



ចំពោះ**ការបង្រៀនបែបសំយោគ** (Hybridized Teaching) គ្រូបង្រៀននៅ NGS ត្រូវបានលើកទឹកចិត្តឱ្យបញ្ចូលនូវវិធីសាស្រ្តផ្សេងៗគ្នាជាមួយគ្នាដែលឆ្លើយតបនឹងបរិបទមូលដ្ឋាន. . .




ការសិក្សាបែបស្ថាបនានិយម
(Constructivism)

- ទ្រឹស្ដីសិក្សាបែបស្ថាបនានិយមផ្ដល់ជាមធ្យោបាយដ៏មានប្រយោជន៍មួយ ដែលគ្រូបង្រៀនអាចបញ្ចូលនូវវិធីសាស្រ្តបង្រៀនពាក់ព័ន្ធផ្សេងៗគ្នាជាមួយគ្នា។
- ការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្ដីនៃការបង្រៀន & រៀនដែលប្រើវិធីសាស្រ្តពាក់ព័ន្ធជាច្រើនដែលបានផ្សព្វផ្សាយកន្លងមកដោយ ក្រសួងអប់រំ យុវជន និងកីឡាដូចជា ការសិក្សាបែបគម្រោង ការសិក្សាអាស្រ័យលើបញ្ហា ។ល។

# ឧទាហរណ៍ពីរបៀបអនុវត្តវិធីសាស្ត្របង្រៀនបែបសំយោគ...

| ឧទាហរណ៍អំពីបរិបទអប់រំ | ល្បិចពាក់ព័ន្ធនឹងវិធីសាស្ត្របង្រៀន | ការអនុវត្តវិធីសាស្ត្របង្រៀនបែបសំយោគ (យុទ្ធសាស្ត្រ) |
|---|---|---|
| ថ្នាក់រៀននៅក្នុងទីជនបទមួយមានសិស្សច្រើនរហូតដល់ ៥០ នាក់។ សិស្សទាំងនេះមិនធ្លាប់រៀនសូត្រ ដែលដឹកនាំដោយខ្លួនឯងពីមុនទេ ហើយបំណិនស្រាវជ្រាវក៏នៅមានកម្រិត។ វត្ថុបំណងសិក្សារបស់គ្រូមានដូចខាងក្រោម៖<br>• សិស្សអាចកំណត់បញ្ហាដែលទាក់ទងនឹងបរិស្ថាននៅក្នុងសហគមន៍របស់ពួកគេ។<br>• សិស្សអាចស្នើដំណោះស្រាយចំពោះបញ្ហាដែលពួកគេបានរកឃើញតាមរយៈការស្រាវជ្រាវនិងការពិភាក្សា។ | **ការសិក្សាបែបសហការ**<br>• រៀបចំសិស្សជាក្រុមចម្រុះសមត្ថភាពពី៤ទៅ៦ក្រុម<br>• បែងចែកតួនាទីចូលរួមធ្វើការងារ<br>• គ្រូបង្រៀនដើរត្រួតពិនិត្យការងារក្រុម<br>• ក្រុមសិស្សធ្វើរបាយការណ៍ ឬបទបង្ហាញ<br>**ការសិក្សាបែបរិះរក**<br>• សិស្សកំណត់សំណួរដែលពួកគេចង់រកចម្លើយ<br>• សិស្សស្រាវជ្រាវ<br>• សិស្សធ្វើបទបង្ហាញ<br>• សិស្សឆ្លុះបញ្ចាំងលើដំណើរការដែលមានដំណើរការល្អ /មិនល្អ<br>**ការសិក្សាអាស្រ័យលើបញ្ហា**<br>• ជំហានទី ១៖ ស្វែងយល់ និងកំណត់បញ្ហា<br>• ជំហានទី ២៖ សិស្សនិយាយពីអ្វីដែលពួកគេបានដឹង...<br>• ជំហានទី ៣៖ សិស្សកំណត់និយមន័យបញ្ហា ...<br>• ជំហានទី ៤៖ សិស្សស្រាវជ្រាវចំណេះដឹង ...<br>• ជំហានទី ៥៖ ស៊ើបអង្កេតរកដំណោះស្រាយ ...<br>• ជំហានទី ៦៖ បង្ហាញ និងគាំទ្រដំណោះស្រាយដែលបានរកឃើញ ...<br>• ជំហានទី ៧៖ សិស្សត្រួតពិនិត្យលទ្ធផលការងារពួកគេឡើងវិញ។ | • គ្រូផ្តល់បញ្ជីបញ្ហាដែលអាចកើតមានក្នុងបរិស្ថាន (ឧទាហរណ៍ ការទុកដាក់សំរាម ការកែឆ្នៃ ការបំពុលខ្យល់ ការបំពុលទឹក) សម្រាប់សិស្សជ្រើសរើសនិងពិចារណាថាតើនេះជាបញ្ហាពិតនៅក្នុងបរិស្ថានរបស់ពួកគេដែរឬទេ។ ល្បិចនេះនៅតែផ្តល់ឱ្យសិស្សគ្រប់គ្រងលើបញ្ហា កំណត់បញ្ហា ប៉ុន្តែត្រូវទទួលស្គាល់ថាសិស្សមិនទាន់ស៊ាំនឹងការរៀនសូត្រដែលដឹកនាំដោយខ្លួនឯងនោះទេ។<br>• គ្រូបង្រៀនរៀបចំក្រុមចំនួន ៥ ក្រុមដែលមួយក្រុមៗមានសិស្សចំនួន ១០ នាក់ ប៉ុន្តែបង្កើនការពិនិត្យតាមដានជួយដើម្បីធានាថាសិស្សទាំងអស់បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការនេះ។<br>• គ្រូប្រគល់កិច្ចការជាក់លាក់ឱ្យក្រុមនីមួយៗ (ឧ. បញ្ជាក់អ្វីដែលគេដឹង កំណត់បញ្ហា ប្រមូលឯកសារស្រាវជ្រាវ។ ល។ )<br>• សិស្សម្នាក់ឬច្រើននាក់ជួយសរសេរលទ្ធផលរកឃើញនិងដំណោះស្រាយ។<br>• សិស្សម្នាក់ឬច្រើនឡើងបង្ហាញពីលទ្ធផលរកឃើញ / ដំណោះស្រាយ. |

# និយមន័យ ការសិក្សាបែបស្ថាបនានិយម...

- ការសិក្សាបែបស្ថាបនានិយមគឺជាទស្សនៈដែលសិស្សសហការគ្នា**បង្កើត**ចំណេះដឹងពីបទពិសោធន៍បុគ្គល និងពីការគិតឆ្លងកាត់បទពិសោធន៍ទាំងនេះ (ការឆ្លុះបញ្ចាំង)។
- តាមរយៈដំណើរការនេះ ពួកគេអាចបង្កើត **ផលិតផល និងគម្រោងចំណេះដឹង**ថ្មីៗ។



នៅក្នុងក្របខណ្ឌគរុកោសល្យ ដែលជំរុញ NGS, ការសិក្សាបែបស្ថាបនានិយម ប្រៀបបាននឹងកំណល់ទ្របង្វិលឱ្យមានការរួមបញ្ចូលគ្នារវាងវិធីសាស្ត្រជាច្រើន ក៏ដូចជាការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងរៀន...






- នេះជាឯកសារក្របខណ្ឌដែលសង្ខេបពីរបៀបដែល NGS ប្រើប្រាស់ការសិក្សាបែបស្ថាបនានិយមដើម្បីលើកកម្ពស់**ការសិក្សាបែបបញ្ញត្តិ** ( Concept-based learning )
- នៅក្នុងឯកសារនេះ **បានបង្រួបបង្រួម**គរុកោសល្យ ដែលលើកកម្ពស់**បំណិនគិតកម្រិតខ្ពស់** និងសម្របសម្រួល**វិធីសាស្ត្រជាច្រើន**ឱ្យនៅក្រោមដំបូលតែមួយ។
- ឯកសារនេះអាចដើរតួជាសៀវភៅណែនាំបណ្តុះបណ្តាលសំខាន់ៗនៅគ្រប់កម្រិត ( ឧ. INSET ឬ PRESET )







# សារៈសំខាន់នៃការសិក្សាបែបគម្រោង...

- ការងារគម្រោងមានសារៈសំខាន់ជាពិសេសនៅក្នុងសាលាជំនាន់ថ្មី ដោយសារតែវិធីសាស្រ្តនេះជួយលើកកម្ពស់ការគិតស៊ីជម្រៅ និងច្នៃប្រឌិត

# វីដេអូអំពីការសិក្សាបែបគម្រោង. . .

- (1136) Project Work Video - YouTube

# ដំណើរការនៃការកែលម្អការអនុវត្តក្នុងថ្នាក់រៀន៖ ការបង្រៀនបែបឆ្លុះបញ្ចាំង. . .




- វិធីសាស្ត្ររៀនថ្មីដែលគ្រូបង្រៀននៅ NGS រៀនមិនគួរឋិតនៅនឹងថ្កល់នោះទេ. . .
- ខណៈដែល ការសិក្សាបែបស្លាបនានិយម គឺជាខ្លឹមសារស្នូលនៃវិធីសាស្ត្ររបស់ NGS ការបង្រៀនបែបឆ្លុះបញ្ចាំងគឺជាដំណើរការមួយដែលនាំទៅរកការផ្លាស់ប្តូរ. . .

# សាលាជំនាន់ថ្មីបានបង្កើតរចនាសម្ព័ន្ធដែលជួយគ្រូបង្រៀនឱ្យឆ្លុះបញ្ចាំងជាទៀងទាត់លើការអនុវត្តរបស់ពួកគេ. . .




- ដំណើរការនៃការផ្លាស់ប្តូរចាប់ផ្តើមជាមួយនឹងការរៀបចំផែនការគន្លងអាជីពនៅដើមឆ្នាំសិក្សា
- ក្រោយមក មានការប្រជុំមួយទល់មួយជាមួយអ្នកផ្តល់ប្រឹក្សាគរុកោសល្យ
- គ្រូប្រឹក្សាគរុកោសល្យនៅតាមសាលារៀននាពេលបច្ចុប្បន្ននេះកំពុងជំនួសបុគ្គលិកអង្គការ ខេប

# ខ្លឹមសារបណ្តុះបណ្តាលសំខាន់ៗផ្សេងទៀតសម្រាប់កសាងសមត្ថភាពនៅ NGS ដែលអាចបញ្ចូលទៅក្នុងសាលារៀនគំរូ រួមមាន៖

| ប្រធានបទពាក់ព័ន្ធ | បរិយាយ |
|---|---|
| គោលការណ៍ស្តីពីការវាស់វែងការសិក្សាសិស្សដើម្បីកែលម្អការវាយតម្លៃអប់រំ | • ការតែងតេស្តដែលមានសុពលភាព<br>• សំណួរលម្អៀង/សំណួរមិនលម្អៀង<br>• ការវិភាគសំណួរ |
| សំណួរប្លូមតាក់សូណូមី | • ការយល់ដឹងពីបំណិនគិត<br>• ការសរសេរវត្ថុបំណងអប់រំ |
| ការសិក្សាបែបសហការ | • ការរៀបចំក្រុម<br>• ការបែងចែកតួនាទីសមាជិកក្រុម |
| ការអប់រំ STEM | • ការរៀបចំដើម្បីជំរុញការពិសោធជាក់ស្តែង |
| ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ | • ការប្រើកុំព្យូទ័រក្នុងការបង្រៀន<br>• ការប្រើសុសវែអប់រំ<br>• ប្រសិទ្ធភាពនៃការប្រើប្រាស់អ៊ីធឺណែត |














# សូមអរគុណ